PRUDENTIAL
ព្រូដិនសល ធានារ៉ាប់រងអាយុជីវិត



# កម្ចីមាន សុវត្ថិភាព

## ផលិតផលធានារ៉ាប់រងអាយុជីវិត ដែលជួយទូទាត់សងបំណុលរបស់អ្នកក្នុងករណីមានគ្រោះអកុសលកើតឡើង








លោកអ្នកមានក្តីស្រមៃជាច្រើន ហើយដើម្បីសម្រេចក្តីស្រមៃទាំងនោះបាន អ្នកអាចការពារកម្ចីរបស់អ្នកជាមួយពួកយើង។

លោកអ្នកអាចទាក់ទងមកកាន់យើងខ្ញុំតាមរយៈ ៖

023 964 222
1800 21 22 23 FREE
info@prudential.com.kh
www.prudential.com.kh
អគារ VTRUST ជាន់ផ្ទាល់ដី #24 ផ្លូវលេខ 169 (មហាវិថីឆេកូស្លូវ៉ាគី) សង្កាត់វាលវង់ ខណ្ឌ 7មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ពួកយើងត្រៀមខ្លួនរួចជាស្រេចក្នុងការឆ្លើយសំណួររបស់លោកអ្នក។

# ហេតុអ្វីត្រូវជ្រើសរើស “កម្ចីមានសុវត្ថិភាព”?

នៅពេលដែលលោកអ្នកកំពុងតាមរកក្តីស្រមៃរបស់អ្នក តើអ្នកនឹងការពារផ្ទះ អាជីវកម្ម និង គ្រួសាររបស់លោកអ្នកពីការទូទាត់បំណុលធនាគារយ៉ាងដូចម្តេច ក្នុងករណីដែលអ្នកជួប គ្រោះអកុសលដែលបណ្តាលឲ្យមរណភាព ឬ ពិការភាពទាំងស្រុង និង ជាអចិន្ត្រៃយ៍ ?



## កម្ចីមានសុវត្ថិភាព

- ក្នុងករណីដែលអ្នកជួបគ្រោះអកុសលដែលបណ្តាលឲ្យអ្នកមិនអាចធ្វើការបានដោយសារតែពិការភាពទាំងស្រុង និង ជាអចិន្ត្រៃយ៍ ឬ បណ្តាលឲ្យអ្នកស្លាប់បាត់បង់ជីវិត នោះកម្ចីរបស់លោកអ្នកនឹងមិនក្លាយជាបន្ទុកសម្រាប់គ្រួសាររបស់អ្នកឡើយ ដោយផលិតផល កម្ចីមានសុវត្ថិភាព នេះនឹងទូទាត់បំណុលរបស់អ្នកដែលនៅសល់រហូតដល់ចំនួននៃទឹកប្រាក់ធានារ៉ាប់រង។

- ផលិតផល កម្ចីមានសុវត្ថិភាព ផ្តល់ជូននូវជម្រើសធានារ៉ាប់រងចំនួនពីរគឺ អត្ថប្រយោជន៍ធានារ៉ាប់រងថយចុះ និងអត្ថប្រយោជន៍ធានារ៉ាប់រងថេរ ទៅលើចំនួនប្រាក់កម្ចី ដែលអនុញ្ញាតឱ្យអ្នកជ្រើសរើសទៅតាមតម្រូវការធានារ៉ាប់រងដែលស្របទៅតាមលក្ខខណ្ឌនៃកម្ចីរបស់អ្នក។



| លក្ខណៈពិសេសរបស់ផលិតផល | |
|---|---|
| | បុព្វលាភធានារ៉ាប់រងតម្លៃសមរម្យ |
| | ធានារ៉ាប់រងទៅលើកម្ចីជាច្រើនប្រភេទដូចជាកម្ចីទិញផ្ទះ កម្ចីពាណិជ្ជកម្ម កម្ចីផ្ទាល់ខ្លួន កម្ចីទិញឡាន ជាដើម |
| | ដំណើរការទិញធានារ៉ាប់រងដែលមានភាពងាយស្រួល |
| | អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមចំនួន 3000 ដុល្លារអាមេរិក ក្នុងករណីមរណភាព ឬ ពិការភាពទាំងស្រុង និង ជាអចិន្ត្រៃយ៍ដោយសារគ្រោះថ្នាក់ចៃដន្យ |
| | ជម្រើសនៃការបង់បុព្វលាភធានារ៉ាប់រង (ការទូទាត់តែមួយលើក ឬ ការទូទាត់ជាប្រចាំមានកាលកំណត់) |



| លក្ខណៈផ្សេងទៀតរបស់កម្ចីមានសុវត្ថិភាព | |
|---|---|
| **ការកំណត់លើអាយុ** | អាយុចាប់ផ្តើមនៃការធានា៖ 18-68 ឆ្នាំ<br>អាយុផុតកំណត់នៃការធានា៖ តិចជាង 70 ឆ្នាំ |
| **រយៈពេលនៃបណ្ណសន្យារ៉ាប់រង** | • ការទូទាត់បុព្វលាភតែមួយលើក៖ 1- 25 ឆ្នាំ<br>• ការទូទាត់បុព្វលាភមានកាលកំណត់៖ 5- 25 ឆ្នាំ (រយៈពេលបង់បុព្វលាភធានារ៉ាប់រងស្មើនឹងរយៈពេលនៃបណ្ណសន្យារ៉ាប់រង – 3ឆ្នាំ) |
| **ចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង** | ទឹកប្រាក់ធានារ៉ាប់រងគឺជាចំនួនធានារ៉ាប់រងដែលអ្នកចង់បានសម្រាប់ការធានា។<br>**ជម្រើសនៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង៖**<br>កម្ចីមានសុវត្ថិភាព មានពីរជម្រើសនៃធានារ៉ាប់រងលើប្រាក់កម្ចីរបស់អ្នក ដែលអនុញ្ញាតឲ្យអ្នកអាចជ្រើសរើសទៅតាមលក្ខខណ្ឌនៃកម្ចីរបស់អ្នក។<br>• អត្ថប្រយោជន៍ធានារ៉ាប់រងថយចុះ ៖ ចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រងរបស់លោកអ្នកនឹងថយចុះជារៀងរាល់ខែនៃបណ្ណសន្យារ៉ាប់រង ហើយក្នុងករណីមរណភាព ឬពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ ចំនួនទឹកប្រាក់ដែលត្រូបានធានារ៉ាប់រងដែលនៅសល់គិតត្រឹមពេលទូទាត់សំណង នឹងផ្តល់ជូនទាំងស្រុង។<br>• អត្ថប្រយោជន៍ធានារ៉ាប់រងថេរ ៖ ចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រងដែលលោកអ្នកបានជ្រើសរើសនៅដើមគ្រានៃបណ្ណសន្យារ៉ាប់រងនឹងនៅថេររហូតដល់បណ្ណសន្យារ៉ាប់រងអស់សុពលភាព ហើយចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង នឹងផ្តល់ជូនលោកអ្នកក្នុងករណីមរណភាព ឬពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ ដែលកើតឡើងនៅក្នុងអំឡុងពេលនៃការធានា។<br>**ការកំណត់លើចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង៖** ចំនួនទឹកប្រាក់តិចបំផុតនៃកម្ចីដែលអាចស្នើសុំបានមានចាប់ពី 1,000 ដុល្លារអាមេរិក។<br>**អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែម** ចំនួន3000ដុល្លារអាមេរិកនឹងផ្តល់ជូនក្នុងករណីមរណភាព ឬ ពិការភាពទាំងស្រុង និង ជាអចិន្ត្រៃយ៍ដោយសារគ្រោះថ្នាក់ចៃដន្យ។ |
| **អ្នកទទួលផល** | អ្នកទទួលផលចម្បងគឺគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ដែលអត្ថប្រយោជន៍ធានារ៉ាប់រងនឹងត្រូវផ្តល់ជូនទៅតាមចំនួនដែលជំពាក់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ហើយចំពោះអត្ថប្រយោជន៍ដែលនៅសល់ (ប្រសិនបើមាន) នឹងត្រូវផ្តល់ជូនឲ្យអ្នកទទួលផលផ្សេងទៀតដែលអ្នកបានចាត់តាំង។ |

សម្គាល់៖ ទឹកប្រាក់សំណងនឹងត្រូវទូទាត់ជូនទៅតាមតារាងអត្ថប្រយោជន៍នៃការធានារ៉ាប់រងដែលបានផ្តល់ជូននៅពេលជាវផលិតផលធានារ៉ាប់រងនេះ ដែលទឹកប្រាក់សំណងអាចនឹងមានទំហំធំជាងឬតូចជាងទំហំនៃកម្ចីដែលនៅសេសសល់។



## ការបង្ហាញពីអត្ថប្រយោជន៍ធានារ៉ាប់រង

លោក សំណាង ចង់ទទួលកម្ចីពីធនាគារចំនួន 10,000 ដុល្លារអាមេរិក ដែលមានរយៈពេល 10ឆ្នាំ។ ដើម្បីធានាថាកម្ចីរបស់គាត់នឹងមិនក្លាយជាបន្ទុករបស់ប្រពន្ធរបស់គាត់ ក្នុងករណីមានគ្រោះអកុសលកើតឡើង លោក សំណាង បានទិញធានារ៉ាប់រងពីក្រុមហ៊ុនព្រូដិនសល កម្ពុជា។ គាត់មានជម្រើសសម្រាប់ការធានារ៉ាប់រងលើកម្ចីរបស់គាត់ ដែលគាត់អាចជ្រើសរើសរវាងអត្ថប្រយោជន៍ធានារ៉ាប់រងថយចុះ និង អត្ថប្រយោជន៍ធានារ៉ាប់រងថេរ។



| ការសង្ខេបពីផលិតផលកម្ចីមានសុវត្ថិភាពរបស់លោកសំណាង | |
|---|---|
| អាយុ | 35 ឆ្នាំ |
| ភេទ | ប្រុស |
| វិធីបង់បុព្វលាភធានារ៉ាប់រង | បុព្វលាភរ៉ាប់រងតែមួយលើក |
| ចំនួនទឹកប្រាក់កម្ចីសរុប | 10,000 ដុល្លារអាមេរិក |
| រយៈពេលនៃបណ្ណសន្យារ៉ាប់រង | 10 ឆ្នាំ |
| បុព្វលាភធានារ៉ាប់រងដែលត្រូវបង់ ប្រសិនបើអត្ថប្រយោជន៍ធានារ៉ាប់រងថេរត្រូវបានជ្រើសរើស | 672.28 ដុល្លារអាមេរិក |
| បុព្វលាភធានារ៉ាប់រងដែលត្រូវបង់ ប្រសិនបើអត្ថប្រយោជន៍ធានារ៉ាប់រងថយចុះត្រូវបានជ្រើសរើស | 446.78 ដុល្លារអាមេរិក |

សម្រាប់ឧទាហរណ៍នេះ តារាងអត្ថប្រយោជន៍នៃការធានារ៉ាប់រងគឺផ្អែកទៅតាមការសន្មត់លើអត្រាការប្រាក់នៃប្រាក់កម្ចីចំនួន ១០ ភាគរយថេរ ក្នុងកំឡុងពេល កម្ចី ហើយសន្មត់ថាពុំមានការទូទាត់កម្ចីមុនកាលកំណត់ ឬយឺតយាវជាងកាលកំណត់នោះទេ។ ក្នុងករណីដែល ទឹកប្រាក់សំណងលើសពីទំហំកម្ចីនៅពេលទូទាត់សំណង នោះអ្នកទទួលផលដែលអ្នកបានចាត់តាំងនឹងទទួលបាន ទឹកប្រាក់ដែលលើសនោះ។ ប៉ុន្តែក្នុងករណីដែល ប្រាក់សំណងមានចំនួនតិចជាងទំហំកម្ចីនៅពេលទូទាត់សំណង នោះក្រុមគ្រួសាររបស់អ្នកនឹងត្រូវទូទាត់នូវចំនួនកម្ចីដែលនៅសល់នោះ ជូនធនាគារ។

## តើវាមានដំណើរការយ៉ាងដូចម្តេច?

ក្នុងករណីមានគ្រោះអកុសលកើតឡើងចំពោះលោក សំណាង ក្នុងឆ្នាំទី៤នៃរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រងរបស់គាត់ ដែលធ្វើឲ្យគាត់ស្លាប់បាត់បង់ជីវិត ឬពិការភាពទាំងស្រុង និង ជាអចិន្ត្រៃយ៍។

### អត្ថប្រយោជន៍ធានារ៉ាប់រងថយចុះ




### អត្ថប្រយោជន៍ធានារ៉ាប់រងថេរ




## ករណីមិនធានាសំខាន់ៗ

ករណីមិនធានាលើ **កម្ចីមានសុវត្ថិភាព** រួមមាន តែមិនចំពោះ៖

**ក.** អត្ថប្រយោជន៍ក្នុងករណីមរណភាព ឬករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយសារករណីគ្រោះថ្នាក់ចៃដន្យ ឬ មិនមែនថ្នាក់ចៃដន្យ៖

- ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះបីជាស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ក្នុងរយៈពេលពីរឆ្នាំគិតចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង
- មេរោគអេដស៍ និង/ឬជម្ងឺណាមួយដែលជាប់ទាក់ទងនឹងមេរោគអេដស៍ រួមទាំងជម្ងឺអេដស៍
- ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល
- ការប្រើគ្រឿងញៀន ឬថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង

**ខ.** អត្ថប្រយោជន៍បន្ថែមក្នុងករណីមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយសារគ្រោះថ្នាក់ចៃដន្យ៖

- ករណីមិនធានានៅក្នុងចំណុច ក
- ការចូលរួមនៅក្នុងសកម្មភាពកីឡាដែលងាយមានគ្រោះថ្នាក់
- ការចូលរួមក្នុងសកម្មភាពអាកាសចរណ៍នានា លើកលែងតែជាអ្នកដំណើរដែលត្រូវបង់ប្រាក់ថ្លៃធ្វើដំណើរ តាមយន្តហោះពហុម៉ាស៊ីន យន្តហោះមានកាលវិភាគធ្វើដំណើរត្រឹមត្រូវ និងយន្តហោះមានអាជ្ញាបណ្ណធ្វើពាណិជ្ជកម្មត្រឹមត្រូវ
- សកម្មភាពសង្គ្រាម ឬអំពើហិង្សា
- រាល់ជម្ងឺដែលបណ្តាលមកពីការខាំ ឬទិច ដោយសត្វល្អិត រួមទាំងមូសខាំ និងដង្កូវ ឬសត្វល្អិតរាតត្បាតក្នុងរាងកាយ។

សូមទៅកាន់ឯកសារនៃបណ្ណសន្យារ៉ាប់រងសម្រាប់ព័ត៌មានបន្ថែមលើករណីមិនធានា។

*នេះគឺជាខិតបណ្ណផ្សព្វផ្សាយសម្រាប់ កម្ចីមានសុវត្ថិភាព និងសម្រាប់ប្រើប្រាស់ចំពោះការផ្សព្វផ្សាយតែប៉ុណ្ណោះ។ សម្រាប់ព័ត៌មានលម្អិត សូមប្រឹក្សាជាមួយ ទីប្រឹក្សាហិរញ្ញវត្ថុ(FC) និងទីប្រឹក្សាធានារ៉ាប់រងអាយុជីវិត(LC)របស់យើង។*